ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ ៣៧៣០០០ អពដ

L202409170151TD3510

ថ្ងៃ ៧ ៩ ១ រោច ខែ ភទ្របទ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៤

# សេចក្តីណែនាំ
## ស្តីពី
## ការអនុវត្តភាតព្វកិច្ចសារពើពន្ធចំពោះការជួលអចលនទ្រព្យ

អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានកិត្តិយសសូមជម្រាបជូនលោក-លោកស្រីជាអភិបាល ឬបណ្ណាធិការរបស់សហគ្រាស ឬកម្មសិទ្ធិករ ដែលធ្វើសកម្មភាពជួលអចលនទ្រព្យឱ្យបានជ្រាបថា ក្នុងរយៈពេលកន្លងមក សហគ្រាស ឬកម្មសិទ្ធិករមួយចំនួនបានធ្វើកិច្ចសន្យាជួលអចលនទ្រព្យ ដល់អតិថិជនជាសិទ្ធិវន្ត ហើយបានទុកពេលមួយរយៈដើម្បីឱ្យអតិថិជនសាងសង់ រចនា ជួសជុល ឬកែលម្អ ដី ឃ្លាំង អគារ ឬការិយាល័យ សម្រាប់គោលដៅអាជីវកម្ម។ ដើម្បីសង្គតិភាពក្នុងការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់ចំណូលនិងអាករលើតម្លៃបន្ថែម អគ្គនាយកដ្ឋានពន្ធដារ សូមធ្វើការណែនាំដូចខាងក្រោម៖

១-កិច្ចសន្យាជួលអចលនទ្រព្យ ដែលមានចែងអំពីការទុករយៈពេលសម្រាប់សាងសង់ រចនា ជួសជុល ឬកែលម្អ ហើយអំឡុងពេលនោះ ម្ចាស់អចលនទ្រព្យមិនគិតថ្លៃឈ្នួលឬគិតថ្លៃឈ្នួលក្នុងកម្រិតណាមួយ ពន្ធលើប្រាក់ចំណូល ពន្ធកាត់ទុកលើថ្លៃឈ្នួលអចលនទ្រព្យ និងអាករលើតម្លៃបន្ថែម ត្រូវអនុវត្តតាមកិច្ចសន្យានោះ។ ការទុករយៈពេលសម្រាប់សាងសង់ រចនា ជួសជុល ឬកែលម្អ មិនត្រូវលើសពី ១០ (ដប់) ភាគរយ នៃរយៈពេលជួលសរុបក្នុងកិច្ចសន្យា។

២-ក្នុងករណីមានកិច្ចសន្យាដូចមានចែងក្នុងចំណុចទី១ ខាងលើ ម្ចាស់អចលនទ្រព្យត្រូវដាក់ជូនរដ្ឋបាលសារពើពន្ធនូវកិច្ចសន្យាជួលអចលនទ្រព្យនោះក្នុងអំឡុងពេល ៣០ថ្ងៃ ក្រោយថ្ងៃចុះកិច្ចសន្យា។

៣-ប្រសិនបើរយៈពេលសម្រាប់សាងសង់ រចនា ជួសជុល ឬកែលម្អ ត្រូវបានពន្យារ ម្ចាស់អចលនទ្រព្យត្រូវស្នើសុំមករដ្ឋបាលសារពើពន្ធដើម្បីពិនិត្យនិងសម្រេច។

អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសង្ឃឹមយ៉ាងមុតមាំថាអភិបាលឬបណ្ណាធិការរបស់សហគ្រាស ឬកម្មសិទ្ធិករ ដែលធ្វើសកម្មភាពជួលអចលនទ្រព្យនៅក្នុងព្រះរាជាណាចក្រកម្ពុជានឹងយកចិត្តទុកដាក់ចូលរួមអនុវត្តតាមខ្លឹមសារនៃសេចក្តីណែនាំនេះប្រកបដោយប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី
ប្រតិភូរាជរដ្ឋាភិបាល
ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ

គង់ វិបុល